**សារព័ត៌មានរបស់ក្រុមប្រឹក្សាអប់រំនៃមណ្ឌលសិក្សាធិការទីក្រុង Philadelphia**

**ស្វាគមន៍ចំពោះព្រឹត្តិបត្រព័ត៌មានរបស់យើង!**
**ចេញផ្សាយលើកទី1៖ រដូវស្លឹកឈើជ្រុះ ឆ្នាំ2021**

ស្វាគមន៍ចំពោះការបោះពុម្ពផ្សាយលើកទីមួយនៃព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាសថ្មីរបស់ក្រុមប្រឹក្សា ដែលអ្នកអាចអាចស្វែងរកដំណឹងថ្មីៗរបស់ក្រុមប្រឹក្សា ខ្លឹមសារសង្ខេបអំពីកំណត់ហេតុត្រួតពិនិត្យវឌ្ឍនភាពគោលដៅនិងលក្ខខណ្ឌកំណត់ និងកំណត់ហេតុតាមប្រតិទិន។

មុនពេលអ្នកបន្តអាន ខ្ញុំសូមទទួលស្គាល់បញ្ហាប្រឈមធ្ងន់ធ្ងរនានាដែលយើងបានជួបប្រទះនៅក្នុងឆ្នាំសិក្សានេះជាមួយនឹងអំពើហិង្សាប្រដាប់អាវុធជាច្រើន មធ្យោបាយធ្វើដំណើរ ការចោលសំរាម និងការរៀបចំបុគ្គលិក -- សព្វគ្រប់បែបយ៉ាង ដោយដោះស្រាយបញ្ហាជំងឺរាតត្បាតវីរុសកូរ៉ូណាដែលចេះតែកើតមានជាបន្តក្នុងពេលជាមួយគ្នានេះផងដែរ។ សូមជ្រាបថា មណ្ឌលសិក្សាធិកានិងក្រុមប្រឹក្សាភិបាល បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីស្វែងរកដំណោះស្រាយ និងដើម្បីឲ្យសិស្សនិងបុគ្គលិករបស់យើងមានសុវត្ថិភាព និងមានសុខភាពល្អ ចាប់តាំងពីពេលដែលការសិក្សាដោយផ្ទាល់បានបន្តអនុវត្ត។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាពអត់ធ្មត់ និងការប្ដេជ្ញាចិត្តរបស់អ្នកចំពោះការអប់រំសាធារណៈនៅក្នុងពេលវេលាដ៏លំបាកនេះ។

សូមអរគុណដែលបានចំណាយពេលវេលាអានសារព័ត៌មានរបស់យើង និងភ្ជាប់ទំនាក់ទំនងជាមួយនឹងក្រុមប្រឹក្សាអប់រំ។ ប្រសិនបើអ្នកមានមតិយោបល់ឬសំណួរណាមួយ សូមផ្ញើអ៊ីម៉ែលមកយើងតាមរយៈ schoolboard@philasd.org។

*Joyce S. Wilkerson ប្រធានក្រុមប្រឹក្សា*

**គោលដៅ និងលក្ខខណ្ឌកំណត់**

**ក្រុមប្រឹក្សាកំណត់សម្គាល់ខ្លឹមសារព័ត៌មានសំខាន់ៗនៅក្នុងម៉ោងត្រួតពិនិត្យវឌ្ឍនភាព**

ក្រុមប្រឹក្សាបានកំណត់សម្គាល់ខ្លឹមសារព័ត៌មានសំខាន់ៗ ចាប់តាំងពីខ្លួនបានចាប់ផ្តើមត្រួតពិនិត្យវឌ្ឍនភាពឆ្ពោះទៅរកគោលដៅ & លក្ខខណ្ឌកំណត់ ផែនការរបស់ក្រុមប្រឹក្សាសម្រាប់ការបង្កើនលទ្ធផលសិក្សារបស់សិស្ស និងការបង្កើតលក្ខខណ្ឌនានាដែលជំរុញដល់ការសិក្សារបស់សិស្ស។ នៅអំឡុងកិច្ចប្រជុំសកម្មភាពប្រចាំខែ សមាជិកក្រុមប្រឹក្សាបានលះបង់ពេលវេលាត្រួតពិនិត្យវឌ្ឍនភាពគោលដៅ ឬលក្ខខណ្ឌកំណត់ ដោយពិនិត្យមើលទិន្នន័យដែលបង្ហាញថាតើមណ្ឌលសិក្សាធិការមានការរីកចម្រើនកម្រិតណានៅក្នុងការសម្រេចបានវត្ថុបំណងរបស់ផែនការ។ ការត្រួតពិនិត្យទិន្នន័យនេះក៏ផ្តល់ដំណឹងផងដែរដល់ការធ្វើសេចក្តីសម្រេចចិត្តរបស់សមាជិកក្រុមប្រឹក្សា នៅពេលពិនិត្យមើលគោលនយោបាយ កញ្ចប់ថវិកា និងគំនិតផ្តួចផ្តើមរបស់មណ្ឌលសិក្សាធិការ។ សូមចូលរួមក្នុងកិច្ចប្រជុំបន្ទាប់ថ្ងៃទី28 ខែតុលា នៅពេលក្រុមប្រឹក្សានឹងពិនិត្យមើលវឌ្ឍនភាពឆ្ពោះទៅរកគោលដៅទី 4 និងទី5 ដែលផ្តោតទៅលើការត្រៀមខ្លួនសម្រាប់មហាវិទ្យាល័យ និងជំនាញអាជីព។

លោកស្រី Joyce Wilkerson ប្រធានក្រុមប្រឹក្សា បានមានប្រសាសន៍ថា៖ “មានខ្លឹមសារព័ត៌មានច្បាស់លាស់មួយចំនួនដែលបានបង្ហាញឲ្យដឹង ចាប់តាំងពីយើងបានចាប់ផ្តើមត្រួតពិនិត្យគោលដៅទាំងនេះ”។ “ទំនោរទាំងនេះបានជួយយើងឲ្យកំណត់នូវតម្រូវការរបស់សិស្សយើង ហើយបន្ទាប់មក ធ្វើការវិនិយោគទៅលើយុទ្ធសាស្ត្រនិងធនធានគោលដៅនានា ដែលអាចឃើញមាននៅក្នុងកញ្ចប់ថវិកា។”

[ស្វែងយល់បន្ថែម]

## បច្ចុប្បន្នភាពព័ត៌មានរបស់ក្រុមប្រឹក្សា

### ក្រុមប្រឹក្សាអប់រំចាប់ផ្តើមស្វែងរកនាយកគ្រប់គ្រងថ្មីមួយរូប

នៅខែសីហា ឆ្នាំ2022 បន្ទាប់ពីបម្រើការងាររយៈពេល 10ឆ្នាំ លោក William R. Hite Jr. បណ្ឌិតផ្នែកអប់រំ នឹងផ្ទេរចេញពីតួនាទីរបស់លោកជាប្រធានគ្រប់គ្រងមណ្ឌលសិក្សាធិការទីក្រុង Philadelphia។ ការស្វែងរកប្រធានគ្រប់គ្រងបន្ទាប់ កំពុងប្រព្រឹត្តទៅជាផ្លូវការ ហើយនឹងត្រូវបានចាត់ចែងដោយក្រុមហ៊ុនស្វែងរកបុគ្គលិកវិជ្ជាជីវៈ។ ការស្រាវជ្រាវកំពុងចាប់ផ្តើមដែលមានការប្រជុំស្តាប់មតិយោបល់ចំនួន 17 លើក ធ្វើឡើងដោយផ្ទាល់និងតាមប្រព័ន្ធអ៊ីនធឺណិតក្នុងរយៈពេល 18ថ្ងៃ ដែលនឹងអញ្ជើញសមាជិកសហគមន៍ឲ្យចូលរួមពិភាក្សាទៅលើបុគ្គលិកលក្ខណៈដែលពួកគេចង់បាននៅក្នុងមុខតំណែងប្រធានគ្រប់គ្រងថ្មី។ លោកស្រី Joyce Wilkerson ប្រធានក្រុមប្រឹក្សា បានមានប្រសាសន៍ថា៖ “មតិយោបល់របស់សហគមន៍នឹងមានសារៈសំខាន់សម្រាប់ក្រុមប្រឹក្សា ក្នុងការកំណត់គុណភាពនិងសមត្ថភាពដែលត្រូវការចាំបាច់ក្នុងមុខតំណែងប្រធានគ្រប់គ្រង ហើយនឹងមានឥទ្ធិពលទៅលើបំណែងចែកភារកិច្ចការងាររបស់យើង”។ “យើងដឹងថាសហគមន៍នេះមានទស្សនៈវិស័យជាក់លាក់ និងមានតម្លៃដែលអាចជួយយើងឲ្យកំណត់បុគ្គលណាម្នាក់ ដែលគួរក្លាយជាប្រធានគ្រប់គ្រងបន្ទាប់របស់យើង។”

សម្រាប់ព័ត៌មានថ្មីៗបំផុតស្តីពីកិច្ចដំណើរការនេះ សូមចូលទៅកាន់គេហទំព័រយើងដោយចុចលើប៊ូតុង “Lear More (ស្វែងយល់បន្ថែម)” នៅខាងក្រោម។

*ស្វែងយល់បន្ថែម*

### ជួបជាមួយអ្នកតំណាងក្រុមប្រឹក្សាសិស្សថ្មីរបស់យើង!

ក្រុមប្រឹក្សាអប់រំបានស្វាគមន៍ និង “បានចាត់តាំង” Rebecca Allen និង Armando Ortez ឲ្យធ្វើជាអ្នកតំណាងក្រុមប្រឹក្សាសិស្សជាផ្លូវការសម្រាប់ឆ្នាំសិក្សា2021-2022 នៅក្នុងកិច្ចប្រជុំសកម្មភាពប្រចាំខែមិថុនា។ នៅក្នុងតួនាទីនេះ Rebecca និង Armando ធ្វើជាតំណាងឲ្យមិត្តភក្តិរបស់ពួកគេដោយចែករំលែកក្តីកង្វល់នានារបស់សិស្សទៅដល់ក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ខ្លួន និងដោយរាយការណ៍អំពីការពិភាក្សានិងសកម្មភាពនានារបស់ក្រុមប្រឹក្សាទៅដល់សិស្សក្នុងសាលាទាំងមូល។

Rebecca ជាសិស្សប្អូននៅវិទ្យាល័យ Central High School ហើយ Armando ជាសិស្សច្បងនៅវិទ្យាល័យ Northeast High School បានចាប់ផ្តើមតួនាទីក្នុងក្រុមប្រឹក្សារបស់ពួកគេនៅថ្ងៃទី19 ខែសីហា។ ពួកគេសង្ឃឹមថានឹងសម្តែងប្រាប់អំពីក្តីកង្វល់របស់សិស្ស និងធ្វើការងារដើម្បីដោះស្រាយបញ្ហាទាំងនោះ ក្នុងគោលបំណងសំខាន់បំផុតក្នុងការកែលម្អបទពិសោធន៍សាលារៀនសម្រាប់សិស្សមណ្ឌលសិក្សាធិការទាំងមូល។

***ស្វែងយល់បន្ថែម***

### ដំណឹងអំពីក្រុមប្រឹក្សាពិគ្រោះយោបល់សម្រាប់ឪពុកម្តាយនិងសហគមន៍

## ក្រុមប្រឹក្សាសូមស្វាគមន៍សមាជិកថ្មីនៃក្រុមប្រឹក្សាពិគ្រោះយោបល់សម្រាប់ឪពុកម្តាយនិងសហគមន៍

នៅក្នុងកិច្ចប្រជុំសកម្មភាពប្រចាំខែសីហា ក្រុមប្រឹក្សាអប់រំបានស្វាគមន៍សមាជិកថ្មីរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់សម្រាប់ឪពុកម្តាយនិងសហគមន៍ (PCAC) ដែលនឹងបំពេញមុខងារក្នុងរយៈពេលពីរឆ្នាំ ចាប់ផ្តើមនៅក្នុងខែសីហា។ សមាជិកថ្មីរួមមាន៖ Jameika Id-Deen, Walette Carter, Tierra Rich, Horace Clouden, Quibila Divine, Jennifer Fisher, Georgia Kiouski, Michael Gorman, Orien Smith Warren, Crystal Green Porter, Najmah Ryan, Tracy Joslyn, Evelyn Reed និង Marilyn Rodriguez។ Rev. Chandra Williams បានចាប់ផ្តើមអាណត្តទីពីរ ចំណែកឯ Christiana Uy និង Elyse Castillo កំពុងតែបញ្ចប់អាណត្តិទីមួយរបស់ពួកគេ។

PCAC បំពេញមុខងារជាស្ពានតភ្ជាប់រវាងសហគមន៍សាលារៀនប្រចាំទីក្រុង និងក្រុមប្រឹក្សាដែលមានសមាជិកក្រុមប្រឹក្សាចែករំលែកព័ត៌មានសំខាន់ៗស្តីពីការងាររបស់ក្រុមប្រឹក្សាទៅកាន់បណ្តាញការងាររបស់ពួកគេ ដោយជម្រាបប្រាប់អំពីក្តីកង្វល់របស់សហគមន៍សាលារៀនរបស់ពួកគេទៅដល់ក្រុមប្រឹក្សា។

[*ស្វែងយល់បន្ថែម*]

## កិច្ចប្រជុំសកម្មភាព

## បច្ចុប្បន្នភាពព័ត៌មានស្តីពីទម្រង់កិច្ចប្រជុំសកម្មភាពរបស់យើង

ពេលនេះ ក្រុមប្រឹក្សាកំពុងរៀបចំកិច្ចប្រជុំសកម្មភាពជាទម្រង់ចម្រុះជាមួយសមាជិកក្រុមប្រឹក្សាភាគច្រើនដែលចូលរួមក្នុងកិច្ចប្រជុំដោយផ្ទាល់ រួមជាមួយនឹងវាគ្មិនចុះឈ្មោះដែលអាចជ្រើសរើសនិយាយដោយផ្ទាល់ឬពីចម្ងាយបាន។ កិច្ចប្រជុំនេះប្រព្រឹត្តទៅបន្ទាប់ពីការរៀបចំកិច្ចប្រជុំជាងមួយឆ្នាំពីចម្ងាយ ដើម្បីគោរពតាមការណែនាំផ្នែកសុខភាពសាធារណៈស្តីពីជំងឺ Covid 19។

## កិច្ចប្រជុំក្រុមប្រឹក្សានាពេលខាងមុខ

- ថ្ងៃទី28 ខែតុលា ឆ្នាំ2021 ម៉ោង 4 ល្ងាច - កិច្ចប្រជុំសកម្មភាពក្រុមប្រឹក្សា
  - ការប្រជុំត្រួតពិនិត្យវឌ្ឍនភាពស្តីពីគោលដៅទី4 និងទី5 ដែលផ្តោតទៅលើការត្រៀមខ្លួនសម្រាប់មហាវិទ្យាល័យនិងអាជីពការងារ
- ថ្ងៃទី4 ខែវិច្ឆិកា ឆ្នាំ2021 ម៉ោង 4 ល្ងាច - កិច្ចប្រជុំរបស់គណៈកម្មាធិការស្តីពីគោលនយោបាយ
- ថ្ងៃទី18 ខែវិច្ឆិកា ឆ្នាំ2021 ម៉ោង 4 ល្ងាច - កិច្ចប្រជុំសកម្មភាពក្រុមប្រឹក្សា
  - ការប្រជុំស្តីពីការត្រួតពិនិត្យវឌ្ឍនភាពស្តីពីលក្ខខណ្ឌកំណត់ទី1៖ សាលាមេត្រី និងមានការគាំទ្រ
- ថ្ងៃទី9 ខែធ្នូ ឆ្នាំ2021 ម៉ោង 4 ល្ងាច - កិច្ចប្រជុំសកម្មភាពក្រុមប្រឹក្សា
  - ការប្រជុំស្តីពីការត្រួតពិនិត្យវឌ្ឍនភាពស្តីពីលក្ខខណ្ឌកំណត់ទី2៖ បទពិសោធន៍សិក្សាសំបូរបែប និងគ្រប់ជ្រុងជ្រោយ

- ការប្រជុំស្តីពីការត្រួតពិនិត្យវឌ្ឍនភាពស្តីពីលក្ខខណ្ឌកំណត់ទី3៖ សហការជាដៃគូជាមួយឪពុកម្តាយ/សមាជិកគ្រួសារ

**អំពីក្រុមប្រឹក្សាអប់រំ**

ក្រុមប្រឹក្សាអប់រំគឺជាស្ថាប័នគ្រប់គ្រងដែលទទួលខុសត្រូវពិនិត្យមើលរាល់គោលនយោបាយ និងការសម្រេចចិត្តលើថវិការបស់មណ្ឌលសិក្សាធិការនៃទីក្រុង Philadelphia។ម្យ៉ាងទៀត ក្រុមប្រឹក្សាអប់រំបំពេញតួនាទីជាអ្នកផ្តល់សិទ្ធិសម្រាប់សាលាឆាតទ័រទាំងអស់នៅក្នុងទីក្រុង Philadelphia។ ក្រុមប្រឹក្សាមានសមាសភាពសមាជិកចំនួនប្រាំបួនរូបដែលត្រូវបានតែងតាំងឡើងដោយចៅហ្វាយក្រុង និងបានបញ្ជាក់ដោយក្រុមប្រឹក្សាក្រុង។ សមាជិកក្រុមប្រឹក្សាបច្ចុប្បន្នរួមមាន៖ Joyce S. Wilkerson ប្រធាន, Leticia Egea-Hinton អនុប្រធាន, Julia Danzy, Mallory Fix-Lopez, Maria McColgan, Lisa Salley, Reginald Streater និង Cecelia Thompson។

**សូមអរគុណសម្រាប់ការអានព្រឹត្តិបត្រព័ត៌មានរបស់យើង!**